**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត
និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

# សេចក្តីណែនាំ
# ស្តីពី
# ការកែសម្រួលការប្រឡងឆមាស

**យោង៖** - ច្បាប់ស្តីពីការអប់រំដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

- អនុក្រឹត្យលេខ ១២៦អនុ្រ.បកស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀនចុះថ្ងៃទី ០៩ កញ្ញា ឆ្នាំ២០០៨
- អនុក្រឹត្យលេខ ៨៩អនក្រ. បកស្តីពីការប្រែក្លាយសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្តនិង វិទ្យាសាស្រ្តសេដ្ឋកិច្ចទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បទបញ្ជាផ្ទៃក្នុងលេខ ៧២៦ សភនវស.បក ស្តីពីការសិក្សាសម្រាប់អនុវត្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ចុះថ្ងៃទី ១៩ មិថុនា ឆ្នាំ ២០១២
- ស្មារតីអង្គប្រជុំគណៈកម្មការវាយតម្លៃការងារបុគ្គលិកថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០១៥
- កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាលអាណត្តិទី៣លើកទី៤ ថ្ងៃព្រហស្បតិ៍ ទី៧ ខែឧសភា ឆ្នាំ២០១៥

ដើម្បីឲ្យការប្រឡងឆមាសប្រព្រឹត្តទៅប្រកបដោយគុណភាព និងប្រសិទ្ធភាព សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចសូមចេញសេចក្តីណែនាំដូចមានចែងខាងក្រោម៖

១. ចាប់ពីឆមាសទី២ឆ្នាំសិក្សា២០១៤-២០១៥ នេះតទៅការប្រឡងឆមាសលែងបង្កើតគណៈកម្មការនានាសម្រាប់ដំណើរការប្រឡងទៀតហើយលើកលែងតែការប្រឡងជ្រើសរើសឲ្យចូលរៀន ការប្រឡងបញ្ចប់ការសិក្សា និងប្រឡងឡើងវិញ។

២. វិញ្ញាសាប្រឡងឆមាសជាវិញ្ញាសាសរសេរ ។

៣. លោក លោកស្រីសាស្ត្រាចារ្យ ត្រូវរ៉ាប់រងដំណើរការប្រឡងឆមាសដោយខ្លួនឯង នៅក្នុងរយៈពេលដែលកំណត់ដោយដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការិយាល័យសិក្សា ឬ ថ្នាក់ក្រោយបរិញ្ញាបត្រ។ សាកលវិទ្យាល័យផ្តល់កម្រៃសេវាចំនួន៣ម៉ោងគុណនឹងអត្រាម៉ោងបង្រៀនជាក់ស្តែងសម្រាប់ការប្រឡងមួយថ្នាក់ សម្រាប់មុខវិជ្ជាឯកទេស លើកលែងតែថ្នាក់ភាសាដោយមិនផ្តល់កម្រៃចេញវិញ្ញាសាជូនទេ។ វិញ្ញាសាប្រឡងត្រូវមានការឯកភាពពីប្រធានអនុប្រធានដេប៉ាតឺម៉ង់នីមួយៗ ឬ នាយក នាយករងថ្នាក់ក្រោយបរិញ្ញាបត្រ។

៤. លោក លោកស្រីសាស្ត្រាចារ្យ ត្រូវគោរពបទបញ្ជាផ្ទៃក្នុងស្តីពីការសិក្សាសម្រាប់អនុវត្តនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ចំពោះបញ្ហាវត្តមាននិស្សិត (អវត្តមាន ដែលមានច្បាប់

អនុញ្ញាតលើសពី ៥០% នៃពេលរៀន=១០ដងឡើងទៅ ឬ អវត្តមានគ្មានច្បាប់អនុញ្ញាតលើសពី៣០% នៃពេលរៀន=៦ដងឡើងទៅ មិនអនុញ្ញាតឲ្យប្រឡងឡើយ)។

៥. វត្តមាននិស្សិតត្រូវផ្ទៀងផ្ទាត់គ្នារវាងលោក លោកស្រីសាស្ត្រាចារ្យ និងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការិយាល័យសិក្សា ឬ ថ្នាក់ក្រោយបរិញ្ញាបត្រ។

៦. ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការិយាល័យសិក្សា និង ថ្នាក់ក្រោយបរិញ្ញាបត្រ ធ្វើបញ្ជីឈ្មោះនិស្សិតប្រឡងឆមាសហើយប្រគល់ជូនលោក លោកស្រី សាស្ត្រាចារ្យ។លោក លោកស្រីសាស្ត្រាចារ្យត្រូវណែនាំនិស្សិតឲ្យចុះហត្ថលេខាលើបញ្ជីវត្តមានក្នុងពេលប្រឡង។ បន្ទាប់ពីប្រឡងចប់ លោក លោកស្រី សាស្ត្រាចារ្យត្រូវប្រគល់បញ្ជីសម្រង់វត្តមាននោះមកឲ្យ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការិយាល័យសិក្សា ឬ ថ្នាក់ក្រោយបរិញ្ញាបត្រ (គ្រូទទួលបន្ទុកថ្នាក់)។ ក្រដាសសម្រាប់និស្សិតសរសេរប្រឡងត្រូវយកពីគ្រូទទួលបន្ទុកថ្នាក់។

៧. លោក លោកស្រី សាស្ត្រាចារ្យមានសិទ្ធិសម្រេចឲ្យចូលប្រឡង ឬ មិនឲ្យចូលប្រឡងចំពោះនិស្សិតដែលមកយឺតក្នុងពេលប្រឡង។

៨. គ្រប់ការប្រឡងត្រូវធ្វើនៅក្នុងបន្ទប់រៀនក្នុងបរិវេណ ស.ភ.ន.វ.ស។

៩. លោក លោកស្រី សាស្ត្រាចារ្យ ត្រូវដាក់ពិន្ទុតាមការកំណត់នៅក្នុង បទបញ្ជាផ្ទៃក្នុង ស្ដីពីការសិក្សានៅ ស.ភ.ន.វ.ស។

១០. លោក លោកស្រី សាស្ត្រាចារ្យត្រូវផ្ដល់ពិន្ទុក្នុងរយៈពេលពីរសប្ដាហ៍យ៉ាងយូរក្រោយពេលប្រឡងមកឲ្យដេប៉ាតឺម៉ង់នីមួយៗ ឬ ថ្នាក់ក្រោយបរិញ្ញាបត្រ។

លោក លោកស្រី សាស្ត្រាចារ្យ ត្រូវមានកាតព្វកិច្ចអនុវត្តសេចក្ដីណែនាំនេះឲ្យមានប្រសិទ្ធភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

សេចក្ដីណែនាំនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**សាកលវិទ្យាធិការ**